ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកំពង់ឆ្នាំង

# របាយការណ៍
# សន្និសីទសារព័ត៌មាន
# ស្តីពី
# ភាពជោគជ័យក្នុងរយៈពេល៥ឆ្នាំកន្លងមក
# របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង

ថ្ងៃព្រហស្បតិ៍ ៥កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៣

# របាយការណ៍
# ក្នុងពិធីសន្និសីទសារព័ត៌មានស្ដីពី «សមិទ្ធផលសម្រេចបានក្នុងរយៈពេល៥ឆ្នាំកន្លងមក»
# របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង

## ១.ស្ថានភាពទូទៅរបស់ខេត្ត

ខេត្តកំពង់ឆ្នាំងស្ថិតនៅភូមិភាគពាយ័ព្យនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយ៩១គីឡូម៉ែត្រពីរាជធានីភ្នំពេញ មានព្រំប្រទល់ខាងកើតទល់នឹងខេត្តកំពង់ចាម-កំពង់ធំ ខាងលិចទល់នឹងខេត្តពោធិ៍សាត់ ខាងត្បូងទល់នឹងខេត្តកំពង់ស្ពឺ-កណ្ដាល ខាងជើងទល់នឹងខេត្តកំពង់ធំ-បឹងទន្លេសាប។

ខេត្តមានផ្ទៃដីសរុបទំហំ ៥៥២ ១០០ហិកតា ចែកជា ៣ផ្នែក៖(១)**តំបន់វាលទំនាប:** ស្ថិតនៅចន្លោះផ្លូវជាតិលេខ៥ និងព្រំប្រទល់ប៉ែកខាងកើតមានទំហំប្រមាណ ១/៣ នៃផ្ទៃដីរួម គ្របដណ្ដប់ផ្ទៃដីស្រុកជលគិរី ស្រុកកំពង់លែង ស្រុកបរិបូណ៌ ក្រុងកំពង់ឆ្នាំង ស្រុកកំពង់ត្រឡាច ។(២) **តំបន់វាលរាប:** ស្ថិតក្នុងចន្លោះផ្លូវជាតិលេខ៥ និងផ្លូវរថភ្លើង គ្របដណ្ដប់ផ្ទៃដីស្រុកបរិបូណ៌ ក្រុងកំពង់ឆ្នាំង ស្រុកកំពង់ត្រឡាច ស្រុករលាប្អៀរ ស្រុកសាមគ្គីមានជ័យ ស្រុកទឹកផុសមានទំហំប្រមាណ ១/៣ នៃផ្ទៃដីរួម។ (៣)**តំបន់ខ្ពង់រាប:** ស្ថិតក្នុងចន្លោះផ្លូវរថភ្លើងទៅព្រំប្រទល់ប៉ែកខាងលិច គ្របដណ្ដប់ស្ទើរទាំងស្រុងនៃស្រុកទឹកផុស និងសាមគ្គីមានជ័យ មានទំហំប្រមាណ ១/៣ នៃផ្ទៃដីរួម ហើយខេត្តមានប្រព័ន្ធផ្លូវគមនាគមន៍សំខាន់ៗ ០៣ខ្សែ ឆ្លងកាត់គឺ៖ កំណាត់ផ្លូវជាតិលេខ៥ ប្រវែង ៩៤គ.ម ផ្លូវរថភ្លើងប្រវែង ៧៣គ.ម និងផ្លូវទឹក(ទន្លេសាប) ប្រវែង ១១០គ.ម ហូរឆ្លងកាត់។

ការគ្រប់គ្រងរដ្ឋបាលដែនដី ខេត្តចែកចេញជា ៨ក្រុង ស្រុក ៧១ឃុំ សង្កាត់ និង ៥៦៩ភូមិ មានប្រជាជនសរុបចំនួន ១៤០ ១៤៨គ្រួសារ ស្មើនឹងចំនួន ៥៧១ ០៦២នាក់ ប្រជាពលរដ្ឋអាយុ ១៨ឆ្នាំឡើងមានចំនួន ៣៨៥ ២០០នាក់ ។ ទំហំគ្រួសារប្រជាជនជាមធ្យម ៤,១៧នាក់/គ្រួសារ ដង់ស៊ីតេប្រជាជនក្នុងខេត្តមានចំនួន ១០៣នាក់/គីឡូម៉ែត្រការ៉េ ។ ប្រជាជនដែលមានអាយុ ១៨ឆ្នាំឡើង មានមុខរបរកសិកម្មជាចម្បងចំនួន ៧២,២% មានមុខរបរសិប្បកម្មជាចម្បងចំនួន ០,៦% និងមានមុខរបរសេវាកម្ម កម្មកររោងចក្រ សហគ្រាសជាចម្បងចំនួន ២៧,២%។

## ២- ការគ្រប់គ្រងរដ្ឋបាលដែនដី សន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ

### ២.១. ការគ្រប់គ្រងរដ្ឋបាលដែនដី

រដ្ឋបាលខេត្ត ក្រុង ស្រុក បានអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល រក្សាបានសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ សោភ័ណភាព និងការអភិវឌ្ឍតាមរយៈយន្តការក្រុមប្រឹក្សា គណៈអភិបាល គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ក្រុង ស្រុក និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ។ ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សាគណៈអភិបាលក្រុង ស្រុក បានអនុវត្តយ៉ាងសកម្មច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងដោយមានការណែនាំពីរាជរដ្ឋាភិបាល ក៏ដូចជាក្រសួងមហាផ្ទៃតាមរយៈអនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានគតិយុត្ត ដើម្បីឲ្យរដ្ឋបាលខេត្ត ក្រុង ស្រុកនៅខេត្តកំពង់ឆ្នាំង បានអនុវត្តប្រកបដោយប្រសិទ្ធភាព។ ក្រុមប្រឹក្សាខេត្តកំពង់ឆ្នាំងអាណត្តិទី៣មានចំនួន ២៣នាក់ (ស្រី ៣នាក់) និងក្រុមប្រឹក្សា ក្រុង ស្រុកអាណត្តិទី៣មានចំនួន ១៤០នាក់ (ស្រី ២៤ នាក់)។ ក្រុមប្រឹក្សាខេត្តបានខិតខំអនុវត្តតួនាទី ដោយមានយន្តការគណៈកម្មាធិការរបស់ក្រុមប្រឹក្សាចំនួន៣ រួមមាន៖ គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈកម្មាធិការកិច្ចការស្ត្រី និងកុមារ គណៈកម្មាធិការលទ្ធកម្ម និងបានដាក់ចេញដីកា សេចក្ដីសម្រេច ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខេត្ត ក្រុង ស្រុក ដើម្បីសម្រេចនូវគោលបំណងក្នុងការធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិតេយ្យនៅថ្នាក់ក្រោមជាតិ ព្រមទាំង

បំពេញមុខងារភារកិច្ចដែលបានប្រគល់ និងបានធ្វើប្រតិភូកម្មស្របតាមច្បាប់កំណត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ បានពង្រឹងការផ្តល់សេវាសាធារណៈស្របតាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាល ពិសេសពង្រឹងការផ្តល់សេវាតាមច្រកចេញចូលតែមួយ ដែលបច្ចុប្បន្នមាននៅសាលាខេត្ត ក្រុង ស្រុកចំនួន ៧ និង ១ស្រុកមានយន្តការច្រកចេញចូលតែមួយ ។

ខេត្តកំពង់ឆ្នាំងមានរដ្ឋបាលឃុំ សង្កាត់ចំនួន ៧១ ឃុំ សង្កាត់ មានក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ៤២៧នាក់ កំពុងសកម្មក្នុងការអនុវត្ត ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ អនុក្រឹត្យ សេចក្តីណែនាំ និងលិខិតបទដ្ឋាន ដែលពាក់ព័ន្ធនានា។ បានគ្រប់គ្រងឲ្យមានអភិបាលកិច្ចល្អ តាមរយៈយន្តការ គណៈកម្មាធិការថែទាំគម្រោង គណៈកម្មាធិការលទ្ធកម្ម គណៈកម្មាធិការកិច្ចការស្ត្រី និងកុមារ គណៈកម្មាធិការថវិកាឃុំ សង្កាត់ ដោយបាន ចាត់ចែងប្រើប្រាស់ធនធាននានា ប្រកបដោយគណនេយ្យភាព តម្លាភាពសម្រាប់ដោះស្រាយបញ្ហា និងសេចក្តី ត្រូវការជាអាទិភាពរបស់ប្រជាជនក្នុងឃុំ សង្កាត់ ដើម្បីបម្រើផលប្រយោជន៍សាធារណៈ ស្របតាមកម្មវិធី នយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។ ក្រុមប្រឹក្សាឃុំ សង្កាត់ គឺជាអ្នកនយោបាយនៅ មូលដ្ឋាន តំណាងឲ្យសម្លេង និងផលប្រយោជន៍របស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ហើយមានគណនេយ្យភាពចំពោះ ប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល។ រដ្ឋបាលឃុំ សង្កាត់ បានបំពេញមុខងារសំខាន់ក្នុងការផ្តល់សេវាសាធារណៈ និងកិច្ចអភិវឌ្ឍសេដ្ឋកិច្ចនៅតាមមូលដ្ឋាន ដោយផ្អែកតាមផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគ បីឆ្នាំរំកិលឃុំ សង្កាត់ ដែលបានរៀបចំ និងអនុវត្តនៅក្នុងអាណត្តិរបស់ខ្លួន លើកកម្ពស់នូវ តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព ឆ្លើយតបតម្រូវការអាទិភាពរបស់ប្រជាជនក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់បានអនុវត្តគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការ និងអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដោយ បានអនុវត្តបញ្ចប់នូវកម្មវិធីជាតិរយៈពេល១០ឆ្នាំដំណាក់កាលទី១ (ឆ្នាំ២០១០-២០២០) សម្រេចបាននូវ សមិទ្ធផលធំៗជាច្រើនពាក់ព័ន្ធនឹងការរៀបចំដាក់ឲ្យដំណើរការស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិគឺ ការប្រកាស ដាក់ឱ្យដំណើរការរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលក្រុង ស្រុក កាលពីចុងឆ្នាំ២០១៩កន្លងទៅ និងបានកំពុងអនុវត្ត មុខងារដែលបានផ្ទេរពីថ្នាក់ជាតិចំនួន ៥៥ និងមុខងាររងចំនួន ១៦២ ។ បច្ចុប្បន្នរដ្ឋបាលខេត្ត ក្រុង ស្រុក និង ឃុំ សង្កាត់ បាននិងកំពុងបន្តជំរុញការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ រាជរដ្ឋាភិបាលឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀត តាមរយៈនៃការអនុវត្ត "**កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍនតាម បែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ រយៈពេល១០ឆ្នាំ ពីឆ្នាំ២០២១-ឆ្នាំ២០៣០**"។

## ២.២. ការងារគណៈបញ្ជាការឯកភាពរដ្ឋបាល

គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត គណៈបញ្ជាការឯកភាពរដ្ឋបាលក្រុង ស្រុកបានយកចិត្តទុកដាក់ លើការអនុវត្តច្បាប់ ថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ សោភ័ណភាព និងការអភិវឌ្ឍ ដោយបានចុះអន្តរាគមន៍ ជួយសង្គ្រោះបានទាន់ពេលវេលា រួមសុខរួមទុក្ខជាមួយប្រជាពលរដ្ឋ ព្រមទាំងបានពង្រឹង និងថែរក្សាសន្តិសុខ នយោបាយ សន្តិសុខសង្គម សុវត្ថិភាពនៅមូលដ្ឋាន តាមរយៈការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ការងារអភិវឌ្ឍន៍សេដ្ឋកិច្ច ជីវភាពប្រជាពលរដ្ឋ ការងារបង្កបង្កើនផល និងការកសាងសមិទ្ធផលនានានៅមូលដ្ឋាន មានការរីកចម្រើនលើគ្រប់វិស័យ។

អាជ្ញាធរមូលដ្ឋានមានការទទួលខុសត្រូវ លើការពង្រឹងសន្តិសុខនយោបាយ សន្តិសុខសណ្តាប់ធ្នាប់ សាធារណៈ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព មានភាពកាន់តែប្រសើរឡើង។

ជាលទ្ធផលចាប់តាំងពីឆ្នាំ ២០១៨-២០២២ ឃុំ សង្កាត់ ទទួលបានចំណាត់ថ្នាក់លេខ១ មានចំនួនកើនឡើង បង្ហាញថា នៅខេត្តកំពង់ឆ្នាំងរក្សាបាននូវសុខសុវត្ថិភាពជូនប្រជាពលរដ្ឋរស់នៅដោយភាពសុខសាន្ត។ ជាក់ស្តែងដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៥ ឆ្នាំ២០២២កន្លងទៅ ខេត្តកំពង់ឆ្នាំង បានដំណើរការយ៉ាងល្អប្រសើរ ត្រឹមត្រូវ សេរី យុត្តិធម៌ ធានាបាននូវសុវត្ថិភាពគ្មានការគំរាមកំហែង គ្មានការបំភិតបំភ័យ គ្មានអំពើហិង្សា ធានាបាននូវសុខសន្តិភាព សុវត្ថិភាព ស្ថិរភាពសង្គម ។

ទន្ទឹមនឹងនោះ រដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងឃុំ សង្កាត់ បានពង្រឹងវិធានការនៃការកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ ការពង្រឹងវិធានការការពារដែនជំរកសត្វព្រៃឱរ៉ាល់ ដីព្រៃរដ្ឋ ព្រៃលិចទឹក ព្រៃសហគមន៍ ដីចំណីផ្លូវច្រាំងទន្លេ ការរក្សាសន្តិសុខជូនថ្នាក់ដឹកនាំចុះបំពេញការងារក្នុងខេត្ត ពិធីបុណ្យជាតិ និងអន្តរជាតិ ។ បានពង្រឹងវិធានការបង្ក្រាបល្បែងស៊ីសង គ្រឿងញៀន បង្ការអគ្គិភ័យ និងបង្ការបង្ក្រាបការជួញដូរមនុស្ស មានវិធានការបង្ការ ទប់ស្កាត់បាននូវការញុះញង់ ភូតកុហកបោកប្រាស់ ការបំផ្លើសការពិត របស់ពួកជនអគតិ និងបានគាំទ្រដល់មន្ទីរ អង្គភាពជំនាញជុំវិញខេត្តក្នុងការអនុវត្តច្បាប់ និងគោលការណ៍នានាក្នុងដែនសមត្ថកិច្ចមន្ទីរ អង្គភាពជាប្រចាំ ។

## ២.៣. ការគ្រប់គ្រងប្រើប្រាស់ដីធ្លី

ការគ្រប់គ្រង និងប្រើប្រាស់ដីធ្លីមានប្រសិទ្ធភាព ត្រូវបានគ្រប់គ្រងកាត់បន្ថយទំនាស់ដីធ្លី ផ្តល់ឲ្យប្រជាពលរដ្ឋយល់ដឹងពីច្បាប់ភូមិបាល និងយល់ដឹងពីសិទ្ធិកាន់កាប់ដីធ្លីត្រឹមត្រូវតាមច្បាប់ដោយប្រើប្រាស់នូវផែនការគ្រប់គ្រង និងប្រើប្រាស់ដីធ្លី។ បានចេញប័ណ្ណកម្មសិទ្ធិជូនប្រជាពលរដ្ឋ តាមរយៈការចុះបញ្ជីដីធ្លីតាមបទបញ្ជាលេខ ០១ បប ស្តីពីការអនុវត្តនយោបាយចាស់សកម្មភាពថ្មីលើវិស័យដីធ្លីរបស់រាជរដ្ឋាភិបាល ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។ ខេត្តបានរៀបចំកម្មវិធីសម្បទានដីសង្គមកិច្ចជូនគ្រួសារស៊ីវិលក្រីក្រ និងកម្មវិធីសម្បទានដីសង្គមកិច្ចជូនកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ។ តាមរយៈយន្តការគណៈកម្មការសុរិយោដី បានជួយធ្វើការដោះស្រាយវិវាទដីធ្លីជូនប្រជាពលរដ្ឋ។ ការប្រើប្រាស់ដីធ្លីទូទាំងខេត្តមានការវិវឌ្ឍន៍ច្រើន ហើយបាននឹងកំពុងប្រមូលផ្តុំទៅលើវិស័យផលិតកម្ម និងការតាំងលំនៅដ្ឋានរបស់ប្រជាជន។ នៅទូទាំងខេត្តភាគរយក្បាលដីដែលមានប័ណ្ណកម្មសិទ្ធិដីធ្លីប្រមាណ៤៤,៥៨%នៃក្បាលដីសរុប ក្រុង/ស្រុកដែលបានរៀបចំផែនការប្រើប្រាស់ដីធ្លីចំនួន៨ ក្រុង/ស្រុក និងឃុំ សង្កាត់ដែលបានរៀបចំផែនការប្រើប្រាស់ដីធ្លី ចំនួន១៦ឃុំ ស្មើ២៥% នៃឃុំ សង្កាត់ទាំងអស់។

❖ ខេត្តមានកម្មវិធីសម្បទានដីសង្គមកិច្ចចំនួន ២ គម្រោងគឺ៖

**ក. សម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ÷** គាំទ្រថវិកាដោយរាជរដ្ឋាភិបាល មានផ្ទៃដីទំហំ ២០៨៨ ហិកតា លើ ២ ទីតាំងស្ថិតក្នុងឃុំក្រាំងល្វា និងឃុំស្វាយជុក ស្រុកសាមគ្គីមានជ័យ។

**ខ. សម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រ÷** មាន ០៤ ទីតាំង ស្ថិតក្នុងឃុំក្រាំងល្វា ២ ទីតាំង ឃុំពាម ១ ទីតាំង និងឃុំឈានឡើង ១ ទីតាំង មានទំហំសរុប ២៧២៧,៦៧ ហិកតា ដែលអនុវត្ត ក្រោមគម្រោងបែងចែកដីដើម្បីសង្គមកិច្ច និងការអភិវឌ្ឍសេដ្ឋកិច្ចដំណាក់កាលទី២ (LASED II) ។

❖ **អំពីការចុះបញ្ជី និងការផ្តល់វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនសម្បទានិក**

បានរៀបចំចុះបញ្ជី និងចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនសម្បទានិកទាំង ០២ គម្រោង ក្នុងដំណាក់កាលទី១ ឆ្នាំ២០១៩ សរុបចំនួន ១ ៥០៦ ប័ណ្ណ ស្មើ៩០៦ គ្រួសារ ក្នុងនោះ៖

**១)-កម្មវិធីសម្បទានដីសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធ និងគ្រួសារ÷** សម្បទានិកដែលត្រូវទទួលបានប័ណ្ណកម្មសិទ្ធិចំនួន ១៧៤ គ្រួសារ ស្មើនឹង ៩៤,៥៦ % នៃចំនួនគ្រួសារសម្បទានិកសរុប ១៨៤ គ្រួសារ ដោយមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុសរុប ២៨៦ ប័ណ្ណ ក្នុងនោះ ដីលំនៅឋានចំនួន ១៤៥ ប័ណ្ណ, ដីកសិកម្មចំនួន ១២៩ ប័ណ្ណ និងដីរដ្ឋចំនួន ១២ ប័ណ្ណ ។

**២)-កម្មវិធីសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រស៊ីវិល÷**សម្បទានិកដែលត្រូវទទួលបានប័ណ្ណកម្មសិទ្ធិចំនួន ៧៣២ គ្រួសារ ស្មើនឹង ៨១,៩៧ %នៃចំនួនគ្រួសារសម្បទានិកសរុប ៨៩៣ គ្រួសារ ដោយមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុសរុប ១ ២២០ ប័ណ្ណ ក្នុងនោះ ដីលំនៅឋានចំនួន ៥៣៥ ប័ណ្ណ, ដីកសិកម្ម ចំនួន ៦៤៤ ប័ណ្ណ និងដីរដ្ឋចំនួន ៤១ ប័ណ្ណ។

នៅក្នុងឆ្នាំ២០២១នេះ គម្រោង LASED II៖ បានបន្តចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចនវត្ថុជំហានទី២ បាន ២៩១ បណ្ណ (ស្មើនឹង ៦៩ %នៃផែនការ) ក្នុងនោះដីលំនៅឋាន ១៨០ បណ្ណ និងដីកសិកម្ម ១១១ ប័ណ្ណ។

**៣)-បច្ចុប្បន្ន កំពុងផ្តួចផ្តើមរៀបចំគម្រោង LASED III ÷** ដោយអនុវត្តគម្រោងលើផ្ទៃដីទំហំ ៥២២ ហិកតា មានទីតាំងនៅភូមិសារអង ឃុំប្រស្នឹប ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដោយកំពុងស្នើសុំអនុបយោគ។

## ៣.សេដ្ឋកិច្ច ជីវភាពប្រជាពលរដ្ឋ

❖ ***វិស័យកសិកម្ម*** ៖ គោលដៅសំខាន់វិស័យកសិកម្មរបស់ខេត្តគឺ ដើម្បីធានាឲ្យបាននូវសន្តិសុខស្បៀង បង្កើនប្រាក់ចំណូល ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពអាហារូបត្ថម្ភសម្រាប់ប្រជាជន តាមរយៈការបង្កើនផលិតភាពកសិកម្មឲ្យកសិករមានបច្ចេកទេសប្រើប្រាស់ពូជ ជី ការដាំដុះបង្កើនរដូវ ការធ្វើពិពិធភាវូបនីយកម្ម ការចិញ្ចឹមសត្វ និងការគាំទ្រសហគមន៍កសិកម្ម ក្នុងការដាំដុះផលិតផលកសិកម្ម ឆ្លើយតបតម្រូវការទីផ្សារ។ ផលិតផលកសិកម្មដំណាំស្រូវ តែងសម្រេចបានលើសផែនការជារៀងរាល់ឆ្នាំ ការគិតគូរតុល្យភាពស្បៀងនៅក្នុងខេត្តនៅសល់ស្រូវអង្ករមួយចំនួនសម្រាប់លក់នៅលើទីផ្សារ និងបានរួមចំណែកលើកស្ទួយជីវភាពប្រជាពលរដ្ឋ។ ជាក់ស្តែងការងារបង្កបង្កើនផលស្រូវឆ្នាំ២០២២ ខេត្តមានដីស្រែវស្សា ១២១ ៨០០ហ.ត ដីស្រែប្រាំងចំនួន ២៦ ៧០០ហ.ត និងដីដាំដំណាំរួមផ្សំ ១៦ ០០០ហ.ត។ តុល្យភាពស្បៀងក្រៅពីស្បៀងហូបចុក ចំណីសត្វ និងទុកពូជ ប្រជាកសិករនៅសល់ស្រូវតាមបណ្តាឆ្នាំគឺ ឆ្នាំ២០១៨ ចំនួន ៣៦០ ១៤១តោន ឆ្នាំ២០១៩ចំនួន ៣៥៨ ៧៤១តោន ឆ្នាំ២០២០ ចំនួន ៤៣៥ ៥៧៣តោន ឆ្នាំ២០២១ចំនួន ៤៨០ ១៧២តោន និងឆ្នាំ២០២២ ចំនួន ៤៨៥ ៧៥០តោន។ ខេត្តមានប្រព័ន្ធធារាសាស្ត្រសរុប ២៤៧កន្លែង មានស្ទឹងសំខាន់ៗ ចំនួន ៣គឺ ស្ទឹងក្រាំងពន្លៃ ស្ទឹងជ្រៃបាក់ និងស្ទឹងបរិបូណ៌ អាចស្រោចស្រពលើផ្ទៃដីស្រែចំការចំនួន ៨៦ ៥០៩ហិកតា។

❖ **ឧស្សាហកម្ម សិប្បកម្ម និងការវិនិយោគ**៖ បច្ចុប្បន្នខេត្តមានរោងចក្រសហគ្រាសចំនួន ២៨រោងចក្រសហគ្រាសមាន៖ រោងចក្រវាយនភ័ណ្ឌកាត់ដេរ សំលៀកបំពាក់ រោងចក្រផលិតផលិតផលធ្វើដំណើរ រោងចក្រកាបូប រោងចក្រផលិតស្រាបៀ និងភេសជ្ជៈ ម៉ាស៊ីនកិនស្រូវ សហគ្រាស ផលិតឱសថ រោងចក្រផលិតផ្លាស្ទិក រោងចក្រផលិតផ្កាគ្រឿងតុបតែង ដែលបានផ្តល់ការងារចំនួន ៥០ ១៨៩នាក់ ក្នុងនោះស្រី ៤០ ៨៤១នាក់។ ខេត្តមានសហគ្រាសធុនតូច មធ្យម និងសិប្បកម្មដែលមានចំនួនសរុប ២ ១៦៣មូលដ្ឋាន ក្រៅពីនោះខេត្តមានសិប្បកម្មខ្នាតតូចលក្ខណៈគ្រួសារ ឬជាសហគមន៍ផ្សេងៗទៀត។ បើប្រៀបធៀបនៅឆ្នាំ២០១៨ ខេត្តមានរោងចក្រ សហគ្រាសចំនួន ១៩ ដែលបានផ្តល់ការងារចំនួន ៤៣ ៧៣១នាក់តែប៉ុណ្ណោះ។

ក្រុមហ៊ុនផលិត និងផ្គត់ផ្គង់ទឹកស្អាតបានគ្របដណ្តប់លើឃុំ សង្កាត់ចំនួន ៤៨ឃុំ សង្កាត់ ស្មើនឹង ៣៤៤ ភូមិ ស្មើនឹង ៦៨,៥៧% ដែលមានគ្រួសារសរុបចំនួន ៨៣ ៧៣៧គ្រួសារបានប្រើប្រាស់ទឹកស្អាត ។ នៅឆ្នាំ២០២២ ថាមពលអគ្គិសនីនៅក្នុងខេត្តបានចែកចាយ និងប្រើប្រាស់ចំនួន ៣៧១ ៨៨៥ ៨០៦Kwh ផ្ទះប្រជាជនដែលមានថាមពលអគ្គិសនីប្រើប្រាស់ចំនួន ១០៩ ៧០៧ខ្នងផ្ទះ ស្មើនឹង៨៥,១៧% នៃខ្នងផ្ទះសរុប និងផ្ទះមានទូរទស្សន៍ប្រើប្រាស់មានចំនួន ១០៣ ១៧៦ខ្នងផ្ទះ ស្មើនឹង៨០,១០% បណ្តាញអគ្គិសនីបាន

គ្របដណ្តប់ ៨៨,១៥% នៃភូមិទូទាំងខេត្ត ។ ឆ្នាំ២០១៨ ខេត្តមានថាមពលអគ្គិសនីចែកចាយ និងប្រើប្រាស់តែចំនួន ២៤៦ ៥១៤ ៥៧០Kwh ហើយផ្ទះប្រជាជនមានថាមពលអគ្គិសនីប្រើប្រាស់ចំនួន ៨៣ ១៩៥ខ្នងផ្ទះ ស្មើនឹង ៦៧,៧៤% នៃខ្នងផ្ទះសរុប និងផ្ទះមានទូរទស្សន៍ប្រើប្រាស់មានចំនួន ៩៧ ៨៣៣ខ្នងផ្ទះ ស្មើនឹង ៧៩,៦៦% បណ្តាញអគ្គិសនីបានគ្របដណ្តប់ ៥៥% នៃភូមិទូទាំងខេត្ត មិនតែប៉ុណ្ណោះរដ្ឋបាលខេត្តបានបំពាក់អំពូលសូឡាបំភ្លឺតាមផ្លូវសាធារណៈ សួនច្បារក្នុងក្រុងកំពង់ឆ្នាំង និងតាមបណ្តាស្រុកក្នុងខេត្ត។

❖ **ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍**

ខេត្តមានផ្លូវសំខាន់ៗឆ្លងកាត់គឺៈផ្លូវជាតិលេខ៥ ប្រវែង៩៣,៩គ.ម (ភ្នំពេញ-កំពង់ឆ្នាំង៩១គ.ម) ផ្លូវជាតិលេខ៥២ប្រវែង ០៨គ.ម ផ្លូវជាតិលេខ៥៣ប្រវែង ៧៣,៥៥០គ.ម ផ្លូវជាតិលេខ៥៣Aប្រវែង ៣០គ.ម ផ្លូវជាតិលេខ៥០Cប្រវែង ៥៧,៤០គ.ម ផ្លូវដែកមានប្រវែង ៧៣គ.ម ផ្លូវទឹកមានប្រវែង ១១០គ.ម (ភ្នំពេញ-កំពង់ឆ្នាំង ១០០គ.ម)។ ក្រៅពីនោះ មានផ្លូវខេត្តក្រាលកៅស៊ូ ផ្លូវបេតុង ផ្លូវក្រាលក្រួសក្រហម និងផ្លូវលំដីសកាត់ខ្វាត់ខ្វែងភ្ជាប់ពីជនបទមកទីប្រជុំជន សម្រាប់សកម្មភាពសេដ្ឋកិច្ច សង្គមកិច្ចរបស់ប្រជាជន។

ខេត្តបានអភិវឌ្ឍបណ្តាញផ្លូវគមនាគមន៍ដោយធ្វើការសាងសង់ ជួសជុលថែទាំ និងការកែលម្អលើកកម្ពស់គុណភាពបណ្តាញផ្លូវថ្នល់កាន់តែប្រសើរឡើង ដោយបានកសាងផ្លូវគមនាគមន៍ក្នុងទីប្រជុំជន និងផ្លូវជនបទជាជំហានៗ ពីផ្លូវលំដីស ផ្លូវក្រាលក្រួសក្រហម មកជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុងដែលបានអនុវត្តគម្រោងដោយក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ មន្ទីរសាធារណការ និងដឹកជញ្ជូន មន្ទីរអភិវឌ្ឍន៍ជនបទ គម្រោងរដ្ឋបាលខេត្ត គម្រោងរដ្ឋបាលក្រុង ស្រុក គម្រោងមូលនិធិឃុំ សង្កាត់ និងគម្រោងរបស់ក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។

គម្រោងហេដ្ឋារចនាសម្ព័ន្ធអនុវត្តដោយរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ បានលទ្ធផលដូចខាងក្រោមៈ

- **គម្រោងហេដ្ឋារចនាសម្ព័ន្ធអនុវត្តដោយរដ្ឋបាលខេត្ត៖** ជួសជុលផ្លូវក្រាលកៅស៊ូ DBST បានចំនួន ១ខ្សែ ប្រវែង ១ ៥០០ម ជួសជុលផ្លូវក្រួសក្រហមរួចចាក់បេតុងអាមេ បានចំនួន ១ខ្សែប្រវែង ៣៧០ម សាងសង់អគារសាលាឃុំក្រាំងដីមាស សាងសង់បណ្ណាគារមួយកន្លែង សាងសង់ឃ្លាំងដាក់សម្ភារៈមួយកន្លែង ជួសជុលរបងជុំវិញសាលាខេត្ត ជួសជុលក្លោងទ្វារខាងលិច និងខាងកើត ជួសជុល និងកែលម្អសួនច្បារចាស់ពីរកន្លែង និងចាក់បេតុងក្នុងសួន ជួសជុលអគារ(អគារចាស់ជំនាន់បារាំង)។ សាងសង់ទីលានទុកដាក់សំរាម សាងសង់ប្រព័ន្ធលូ និងស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់ក្រុងកំពង់ឆ្នាំង។
- **គម្រោងហេដ្ឋារចនាសម្ព័ន្ធអនុវត្តដោយរដ្ឋបាលក្រុង ស្រុក៖** កសាងផ្លូវបេតុងប្រវែង ១៧,៧៨២គ.ម ផ្លូវក្រាលក្រួសក្រហម ប្រវែង ១៦៥,៨៤៨គ.ម ជួសជុលផ្លូវដីស ប្រវែង ៥៥,៥៤៥គ.ម សួនច្បារ ៣កន្លែង សាងសង់របងសាលាស្រុក ១៤៥ម៉ែត្រ ដាំបង្គោលភ្លើង សាងសង់ចំណតរថយន្ត ម៉ូតូ ១ កន្លែង និងជួសជុលអគារសាលាក្រុង ស្រុក ២ខ្នង។
- **គម្រោងហេដ្ឋារចនាសម្ព័ន្ធអនុវត្តដោយរដ្ឋបាលឃុំ សង្កាត់៖** សាងសង់ផ្លូវបេតុង ប្រវែង ៦១៦,៧៧៩គ.ម ផ្លូវក្រាលក្រួសក្រហមប្រវែង ៣៨ ២៦៣,៧៦៧គ.ម ផ្លូវក្រាលក្រួសធម្មជាតិប្រវែង ១៤៩,៨២១គ.ម ផ្លូវលំដីសប្រវែង ៤២,៦៤៧គ.ម ប្រឡាយប្រវែង ៦,៨២១គ.ម សាងសង់សាលាមត្តេយ្យ ១៣សាលា សាងសង់ស្ពានបេតុង ៣,៤៦៨គ.ម ទ្វារទឹក ៦កន្លែង។

ក្រៅពីគម្រោងហេដ្ឋារចនាសម្ព័ន្ធអនុវត្តដោយរដ្ឋបាលខេត្ត រដ្ឋបាលក្រុង ស្រុក និងរដ្ឋបាលឃុំ សង្កាត់ ខេត្តទទួលបានសមិទ្ធផលជាច្រើនដែលរាជរដ្ឋាភិបាលបានផ្តល់ឲ្យខេត្តកំពង់ឆ្នាំង ដែលអនុវត្តតាមរយៈក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងស្ថាប័នពាក់ព័ន្ធ មន្ទីរសាធារណការ និងដឹកជញ្ជូន និងមន្ទីរអភិវឌ្ឍន៍ជនបទ ។ សូចនាករវាស់វែងភាពរីកចម្រើនវិស័យហេដ្ឋារចនាសម្ព័ន្ធរបស់ខេត្តបានបង្ហាញថា នៅឆ្នាំ២០១៨ ខេត្តមានផ្លូវជាតិមួយលេខ ពីរលេខ ក្រាលកៅស៊ូមានប្រវែង ១៤៩,៨គ.ម ផ្លូវខេត្ត និងផ្លូវក្នុងក្រុងកំពង់ឆ្នាំងជាប្រភេទផ្លូវក្រាលកៅស៊ូ និងបេតុងប្រវែង ៨១,៧៣គ.ម ផ្លូវនៅតាមជនបទក្រាលកៅស៊ូ និងបេតុងប្រវែង ១២៣គ.ម កំពង់ផែចំនួន ៥ ។ នៅឆ្នាំ២០២២ ខេត្តមានផ្លូវជាតិមួយលេខ ពីរលេខ ក្រាលកៅស៊ូមានប្រវែង ១៩៩,៨៤គ.ម ផ្លូវខេត្ត និងផ្លូវក្នុងក្រុងកំពង់ឆ្នាំងជាប្រភេទផ្លូវក្រាលកៅស៊ូ និងបេតុងប្រវែង ៣៣១,៩២គ.ម ផ្លូវជនបទក្រាលកៅស៊ូ និងបេតុងប្រវែង ៥៤៤,៥៩គ.ម និងកំពង់ផែចំនួន៧ ។

អភិវឌ្ឍន៍ជនបទ គឺជាការងារអន្តរវិស័យមួយដែលគ្របដណ្តប់លើវិស័យហេដ្ឋារចនាសម្ព័ន្ធជនបទ សុខាភិបាល អប់រំ កសិកម្ម ការផ្គត់ផ្គង់ទឹក អនាម័យ និងវិស័យដ៏ទៃទៀតនៃការអភិវឌ្ឍ សង្គម សេដ្ឋកិច្ច នៅតំបន់ជនបទរបស់ខេត្ត បានជំរុញការអភិវឌ្ឍជនបទ បង្កើនលទ្ធភាព និងសមត្ថភាពដល់សហគមន៍មូលដ្ឋានលើការរៀបចំផែនការ ការគ្រប់គ្រងអភិវឌ្ឍន៍នៅមូលដ្ឋានមានការរីកចម្រើនគួរកត់សំគាល់ ។ ខេត្តបានជំរុញការងារវិស័យទឹកស្អាត បរិស្ថាន និងអនាម័យជនបទ ជាពិសេសការអនុវត្តផែនការជំរុញឲ្យប្រជាពលរដ្ឋនៅគ្រប់ភូមិ ឃុំទូទាំងខេត្តបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល ដើម្បីលើកកម្ពស់សុខមាលភាពសាធារណៈ អនាម័យក្នុងគ្រួសារ ទប់ស្កាត់បាននូវជំងឺដង្កាត់ផ្សេងៗ និងសម្រេចឲ្យបានការប្រកាសទទួលស្គាល់ខេត្តកំពង់ឆ្នាំងជាផ្លូវការ ថាជាខេត្តបញ្ចប់ការបន្ទោបង់ពាសវាលពាសកាល (ODF) ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនាពេលខាងមុខ។

❖**ទេសចរណ៍** ៖ ខេត្តមានតំបន់ទេសចរណ៍ចំនួន ២៤កន្លែង ក្នុងនោះតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រមាន ១០កន្លែង តំបន់ទេសចរណ៍ធម្មជាតិមាន ១៤កន្លែង សណ្ឋាគារ ១០កន្លែង ផ្ទះសំណាក់ ៥៣កន្លែង ភោជនីយដ្ឋាន អាហារដ្ឋានមាន ១១៦កន្លែង ហើយក្រុងកំពង់ឆ្នាំងមានសួនច្បារ ៧កន្លែង។ នៅឆ្នាំ២០១៩ ពិធីបុណ្យទន្លេលើកទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចតេជោ និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** មានភ្ញៀវទេសចរណ៍ជាតិ អន្តរជាតិ បានមកកម្សាន្ត និងស្នាក់នៅក្នុងខេត្ត ចំនួន ១ ១៥៧ ៨៥៥នាក់ ក្នុងនោះភ្ញៀវទេសចរណ៍ជាតិ ១ ០២៩ ៨៣៨នាក់ និងភ្ញៀវអន្តរជាតិចំនួន ១២៨ ០១៧នាក់ ។ ចាប់តាំងពីដើមឆ្នាំ២០២០ ប្រទេសទូទាំងពិភពលោករួមទាំងកម្ពុជាយើងបានរងផលប៉ះពាល់ដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩ នៅខេត្តកំពង់ឆ្នាំងមានការថយចុះភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិ ប៉ុន្តែនៅឆ្នាំ២០២២ ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានធ្វើឲ្យស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជាមានលក្ខណៈល្អប្រសើរបំផុត ហើយ **សម្តេចតេជោ** បើកដំណើរការប្រទេសឡើងវិញលើគ្រប់វិស័យ ដែលជាកត្តាកំណត់មួយដើម្បីស្តារ និងរក្សាស្ថិរភាពលំនឹងផ្នែកសង្គម សេដ្ឋកិច្ច ក្រោយទទួលរងផលប៉ះពាល់នៅក្នុងវិបត្តិសាកលដ៏ធ្ងន់ធ្ងរមួយនេះ។ ក្រោយបើកដំណើរការប្រទេសឡើងវិញ ប្រជាជនខេត្តកំពង់ឆ្នាំងក៏ដូចទូទាំងប្រទេសមានភាពសប្បាយរីករាយធ្វើបុណ្យទានតាមប្រពៃណី បុណ្យជាតិ និងព្រឹត្តិការណ៍ផ្សេងៗដែលមានការចូលរួមពីភ្ញៀវទេសចរណ៍ជាតិ អន្តរជាតិយ៉ាងច្រើនកុះករ និងសប្បាយរីករាយ។

✧ **បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍៖** នៅខេត្តមានស្ថានីយវិទ្យុអេសអឹម(FM)របស់រដ្ឋចំនួន ០១ស្ថានីយ ស្ថានីយវិទ្យុអេសអឹម(FM)របស់ឯកជនចំនួន ១៦ស្ថានីយ ស្ថានីយវិទ្យុបណ្តាញមានចំនួន ០២ស្ថានីយ និងស្ថានីយទូរទស្សន៍ខ្សែកាបមានចំនួន ០៩ស្ថានីយ ។ វិស័យព័ត៌មាននៅក្នុងខេត្ត ប្រជាជនបានទទួលសេវាព័ត៌មានផ្តល់ការអប់រំ និងការកំសាន្តប្រកបដោយគុណភាព សមធម៌តាមរយៈមធ្យោបាយផ្សេងគ្នាដូចជាទូរទស្សន៍ វិទ្យុ សារព័ត៌មានបោះពុម្ព ប្រព័ន្ធអ៊ីនធឺណិត និងតាមបណ្តាញសង្គម ។ ស្ថានីយ៍វិទ្យុនៅខេត្តក្លាយជាស្ពានភ្ជាប់រាជរដ្ឋាភិបាលជាមួយប្រជាជនសម្រាប់ផ្តល់ព័ត៌មាន គោលនយោបាយលើគ្រប់វិស័យរបស់រាជរដ្ឋាភិបាលទៅដល់ប្រជាជន ដើម្បីឱ្យប្រជាជនបានចូលរួមអនុវត្ត និងទទួលព័ត៌មានលើប្រធានបទអប់រំ សង្គម សិទ្ធិ ច្បាប់ សុខភាព និងជីវភាពរស់នៅប្រចាំថ្ងៃ ។ បច្ចុប្បន្នសេវាប្រៃសណីយ៍ និងទូរគមនាគមន៍របស់ខេត្តរួមមាន៖ ខេត្តមានសេវាទូរស័ព្ទអចល័តចំនួន ២ក្រុមហ៊ុន និងសេវាទូរស័ព្ទចល័តចំនួន ៤ក្រុមហ៊ុនមានសេវាគ្របដណ្តប់ទូទាំងខេត្ត មានអង់តែនទូរស័ព្ទចំនួន ៣៦០បង្គោល ព្រមទាំងមានសេវា(EMS) គឺជាសេវាលិខិតឆ្លើយតបឆាប់រហ័សដែលមានអាទិភាពខ្ពស់បំផុតរបស់ប្រៃណីយ៍កម្ពុជា សេវានេះបានឆ្លើយតបទៅនឹងតម្រូវការទំនាក់ទំនងតាមរយៈលិខិតរបស់ប្រជាជនដែលមានតម្លៃថោក លឿន សាមញ្ញ តែគួរឱ្យទុកចិត្តបានចាប់តាំងពីពេលទទួល បញ្ជូនចេញ រហូតដល់ពេលចែកចាយ។

✧ **សេដ្ឋកិច្ចរបស់ខេត្តកំពង់ឆ្នាំង៖** លទ្ធផលគណនាផលិតផលក្នុងស្រុកសរុបឆ្នាំ២០១៨ សេដ្ឋកិច្ចខេត្តមានទំហំ ៧៨១លានដុល្លារ ដែលមានសមាមាត្រពីវិស័យកសិកម្មមានចំនួន ៥៦,៦% វិស័យឧស្សាហកម្មសិប្បកម្ម និងសំណង់មាន២៤,៨% និងចំណូលពីវិស័យសេវាកម្មមាន ១៨,៦%។ ចំណូលប្រចាំឆ្នាំរបស់ប្រជាពលរដ្ឋម្នាក់ៗចំនួន ១ ៣៩៥,១ដុល្លា/ឆ្នាំ។ ឆ្នាំ២០២១ ទំហំសេដ្ឋកិច្ចរបស់ខេត្តមានចំនួន ៣ ៧៤១ ៦៦១ លានរៀល គិតជាដុល្លាប្រហែល ៩១៨លានដុល្លារ ស្មើ ៣% នៃសេដ្ឋកិច្ចជាតិ។ វិស័យកសិកម្មមានអត្រាចូលរួម ៥៦,៧% វិស័យឧស្សាហកម្មមានអត្រាចូលរួមចំនួន ២៥,៧% និងការចូលរួមពីវិស័យសេវាកម្មមានចំនួន ១៧,៦% ផលិតផលក្នុងស្រុកសរុបសម្រាប់មនុស្សម្នាក់ក្នុងឆ្នាំ២០២១ ចំនួន ១ ៥៦៣,៧ដុល្លាអាមេរិក។ ទោះបីសេដ្ឋកិច្ចខេត្តទាបជាងថ្នាក់ជាតិ តែខេត្តមានមោទនភាពចំពោះលទ្ធផលនៃការអភិវឌ្ឍ បានបង្ហាញវឌ្ឍនភាពតាមសូចនាកររីកចំរើនដូចបានជម្រាបជូនខាងលើ និងឆ្លុះបញ្ចាំងតាមរយៈកម្រិតជីវភាពរស់នៅរបស់ប្រជាជនជាក់ស្តែងតាមមូលដ្ឋានមានការកើនឡើង។

## ៤.សង្គមកិច្ច សុខុមាលភាពប្រជាជន

✧ **អប់រំយុវជន យុវជន និងកីឡា៖** ខេត្តបានយកចិត្តទុកដាក់ការពង្រឹងគុណភាពអប់រំ ស្របតាមគោលដៅជាអាទិភាពរបស់រាជរដ្ឋាភិបាល លើការអភិវឌ្ឍធនធានមនុស្ស។ បានលើកកម្ពស់គុណភាព ប្រសិទ្ធភាពសេវាអប់រំ តាមរយៈការបង្កើនការផ្គត់ផ្គង់សម្ភារៈសិក្សា សកម្មភាពបណ្ណាល័យ កំណែទម្រង់កម្មវិធីសិក្សា ការផ្តល់អាហារូបករណ៍ដល់សិស្សក្រីក្រ..។ល។ លទ្ធផលប្រលងមធ្យមសិក្សាទុតិយភូមិ អត្រាសិស្សប្រឡងជាប់ខ្ពស់ និងសិស្សទទួលបាននិទ្ទេស A មានការកើនឡើងជារៀងរាល់ឆ្នាំ ជាក់ស្តែងនៅឆ្នាំសិក្សា២០២២ កន្លងទៅ ខេត្តកំពង់ឆ្នាំងមានសិស្សនិទ្ទេស A ចំនួន ២៧នាក់។ បច្ចុប្បន្នខេត្តមានគ្រឹះស្ថានសិក្សាចំណេះទូទៅទាំងសាធារណៈ និងឯកជនមានចំនួន ៦៤១កន្លែងរួមមាន៖ មត្តេយ្យសិក្សា មានសរុបចំនួន ២៦៤កន្លែង ក្នុងនោះ មត្តេយ្យរដ្ឋចំនួន ១៨ មត្តេយ្យសិក្សាឯកជនចំនួន ១០ និងមត្តេយ្យសិក្សាសហគមន៍ ២៣ កន្លែង។ បឋមសិក្សាមានសរុបចំនួន ២៩៣កន្លែង ក្នុងនោះបឋមសិក្សារដ្ឋចំនួន ២៧៩កន្លែង បឋមសិក្សាឯកជន

ចំនួន ១៤ កន្លែង។ អនុវិទ្យាល័យមានសរុបចំនួន ៦៥កន្លែង ក្នុងនោះអនុវិទ្យាល័យរដ្ឋ មានសរុបចំនួន ៦២កន្លែង អនុវិទ្យាល័យឯកជនមានចំនួន ៣កន្លែង និងវិទ្យាល័យមានចំនួន ១៩កន្លែង ក្នុងនោះអនុវិទ្យាល័យរដ្ឋមានសរុបចំនួន ១៦កន្លែង វិទ្យាល័យឯកជនមានចំនួន ៣កន្លែង។ ប្រជាពលរដ្ឋខេត្តកំពង់ឆ្នាំង បានទទួលនូវអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចតេជោ** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** រួមមាន ៖ អគារសិក្សាចំនួន ១៧៤ ខ្នង ស្មើនឹង ១១៤៦បន្ទប់ក្នុងនោះរួមមាន៖ អគារសិក្សាសរុប ១៤២ខ្នង ស្មើនឹង ១ ០១៩បន្ទប់ ទីចាត់ការសរុប ១៤ខ្នង ស្មើនឹង ៤២បន្ទប់ អគារស្នាក់នៅ ៥ខ្នង ស្មើនឹង ៥០បន្ទប់ បណ្ណាល័យ ៥ខ្នង ស្មើនឹង ១៣បន្ទប់ អគារកាត់ដេរ ៨ខ្នង ស្មើនឹង ២២បន្ទប់ ម៉ាស៊ីនដេរ ៤០០គ្រឿង និងសមិទ្ធផលយ៉ាងច្រើនសន្ធឹកសន្ធាប់ទៀតរាប់មិនអស់ និងមិនអាចកាត់ថ្លៃបាន។

❖ **សុខាភិបាល៖** បច្ចុប្បន្នខេត្តមានមូលដ្ឋានសុខាភិបាលសាធារណៈចំនួន ៥០កន្លែង គឺមន្ទីរពេទ្យខេត្ត និងមន្ទីរពេទ្យបង្អែកស្រុកចំនួន ០៣កន្លែង មណ្ឌលសុខភាពចំនួន ៤៥កន្លែង ប៉ុស្តិ៍សុខភាពចំនួន ០២កន្លែង បម្រើសេវាសុខភាពជូនប្រជាពលរដ្ឋ ២៤ម៉ោង/២៤ម៉ោង ដែលនៅឆ្នាំ២០១៨ ខេត្តមានមណ្ឌលសុខភាពចំនួន ៤២កន្លែងតែប៉ុណ្ណោះ។ បានយកចិត្តទុកដាក់ផ្តល់សេវាជូនប្រជាជន លើកកម្ពស់សុខភាពមាតា ទារក កុមារ ប្រយុទ្ធនឹងជំងឺឆ្លង ជំងឺមិនឆ្លង អាហារូបត្ថម្ភរបស់ប្រជាជនទូទៅ សុខភាពបន្តពូជ និងជំរុញឱ្យមានការផ្លាស់ប្តូរទម្លាប់រស់នៅដើម្បីសុខភាព។ ក្នុងពេលរីករាលដាលនៃជំងឺកូវីដ-១៩កន្លងទៅខេត្តបានរៀបចំជាប៉ុស្តិ៍ផ្តល់ថ្នាំបង្ការ ចាក់វ៉ាក់សាំងចំនួន ៥៣ក្រុម ក្នុងនោះមានក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **ឯកឧត្តម ហ៊ុនម៉ានី** ចំនួន ១២ក្រុម កងទ័ពអាកាស ៣ក្រុម និងតំបន់ប្រតិបត្តិការសឹករងកំពង់ឆ្នាំង ២ក្រុម។ រដ្ឋបាលខេត្តបានរៀបចំមណ្ឌលចត្តាឡីស័ក សម្រាប់ទទួលពលករ និងអ្នកចំណាកស្រុក ដើម្បីធ្វើចត្តាឡីស័កមុនការចូលទៅរស់នៅក្នុងសហគមន៍ បានតាមតម្រូវការ និងទាន់ពេលវេលា។ ក្នុងបរិបទការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ទូទាំងខេត្តកំពង់ឆ្នាំងមានអ្នកវិជ្ជមានកូវីដ-១៩ សរុបចំនួន ៤ ៩៧៥នាក់ បានព្យាបាលឱ្យជាសះស្បើយសរុប ៤ ៧៩៧ នាក់ មានអ្នកស្លាប់សរុប ១៧៨នាក់។ បច្ចុប្បន្នការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ដូសទី១បានចំនួន ៥០៧ ៣៦៧នាក់ ស្មើនឹង១០២,៣១% ដូសទី២បានចំនួន ៤៧៣ ៥៨៥នាក់ ស្មើនឹង៩៥,៥០% ដូសទី៣បានចំនួន ៣០៣ ៨៧២នាក់ ស្មើនឹង៦១,២៨% ដូសទី៤បានចំនួន ១៣០ ៣៩៥នាក់ ស្មើនឹង២៦,២៩% និងដូសទី៥ បានចំនួន ៤២ ២៨២នាក់ ស្មើនឹង៨,៥៣%។

❖ **សង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា៖** បានពង្រឹង និងពង្រីកសេវាសុខុមាលភាពសង្គម សម្រាប់ជនក្រីក្រងាយរងគ្រោះ សេវាសុខមាលភាពកុមារ យុវនីតិសម្បទា សេវាសុខុមាលភាពជនពិការ និងស្តារលទ្ធភាពពលកម្ម របបសន្តិសុខសង្គម សុខមាលភាពមនុស្សចាស់ សុខមាលភាពអតីតយុទ្ធជនមន្ត្រីរាជការស៊ីវិល ប្រជាជនទូទៅ និងបានអនុវត្តសេវាសង្គមកិច្ចសម្រាប់ជួយជនរងគ្រោះ ជនងាយរងគ្រោះ និងអន្តរាគមន៍សង្គមកិច្ចជួយដល់ប្រជាជនក្រីក្រងាយរងគ្រោះ និងជនរងគ្រោះមហន្តរាយផ្សេងៗ។ ដោះស្រាយបញ្ហាជនអនាថា ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអនុវត្តច្បាប់ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ។ បានជំរុញកម្មវិធីអប់រំសីលធម៌សង្គមតម្លៃស្រ្តី និងគ្រួសារខ្មែរ សំដៅពង្រីកវប្បធម៌អហិង្សាក្នុងគ្រួសារ និងសហគមន៍។ បច្ចុប្បន្នខេត្តកំពុងអនុវត្តគោលនយោបាយគាំពារសង្គមរបស់រាជរដ្ឋាភិបាលដែលបាន និងកំពុងដំណើរការបើកប្រាក់ឧបត្ថម្ភជូនគ្រួសារក្រីក្រ ២៧ ៧៨២ គ្រួសារ

ថវិកាដែលបានបើកផ្តល់ចាប់តាំងពីចាប់ផ្តើមកម្មវិធីសរុបចំនួន ១៤៥ ៤៥៤ ៩៧៦ ០០០រៀល។ គិតចាប់ពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែមករា ឆ្នាំ២០២៣ បានបើកប្រាក់ឧបត្ថម្ភជូនស្ត្រីមានផ្ទៃពោះចំនួន ៥ ០៧៦នាក់ និងកុមារអាយុក្រោម២ឆ្នាំចំនួន ១ ៧៤៥នាក់ អស់ថវិកាសរុបចំនួន ២ ៧១៣ ៨០០ ០០០ រៀល ។ ចាប់ពីខែមករា រហូតដល់ខែវិច្ឆិកា ឆ្នាំ២០២២ បានផ្តល់ប្រាក់បន្ថែមរបស់រាជរដ្ឋាភិបាលជូន កម្មករ និយោជិកជាស្ត្រីនៅពេលសម្រាលកូនមានចំនួន ២ ៧៦២នាក់ សរុបទឹកប្រាក់ចំនួន ១ ១១៣ ៦០០ ០០០ រៀល និង ចាប់ពីថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២២នេះ ខេត្តកំពុងដំណើរការបើកផ្តល់សាច់ប្រាក់ដល់គ្រួសារងាយរងហានិភ័យរងគ្រោះដោយទឹកជំនន់ និងគ្រួសារងាយរងហានិភ័យរងគ្រោះដោយសម្ពាធអតិផរណាចំនួន ២១ ៧៤៤នាក់។

ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងមានការចង្អុលការផ្ទាល់ពី **ឯកឧត្តម នាយឧត្តមសេនីយ៍កិត្តិសង្គហបណ្ឌិត គន់ គីម** ប្រធានគណៈកម្មាធិការសមាគមអតីតយុទ្ធជនកម្ពុជា បានដោះស្រាយរាល់កង្វះខាត របស់បងប្អូនអតីតយុទ្ធជនដែលជាកិច្ចឆ្លើយតបទៅនឹងគុណបំណាច់បងប្អូនដែលបានលះបង់ក្រុមគ្រួសារ ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង ហ៊ានបូជាជីវិតដើម្បីរំដោះប្រទេសជាតិគ្រប់ដំណាក់កាល។ គណៈកម្មាធិការសមាគមអតីតយុទ្ធជនកម្ពុជាខេត្តបានចុះប្រគល់ថវិកាបេឡាមរណសង្គ្រោះជូនគ្រួសារសព ចុះសួរសុខទុក្ខ ជូនអំណោយសមាជិកតាមគេហដ្ឋាន និងបានសហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជនខេត្ត បានចុះប្រគល់ថវិកាធានារ៉ាប់រងសង្គមជូនគ្រួសារសពអតីតយុទ្ធជន និងសហការជាមួយមន្ទីរសុខាភិបាល ចុះចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនអតីតយុទ្ធជន និងគ្រួសារ ។ ខេត្តបានធ្វើពិធីចាប់ឆ្នោតប្រគល់ដី ផ្ទះ ជូនបងប្អូនអតីតយុទ្ធជន និងគ្រួសារចំនួន ១០០ខ្នងផ្ទះ និងត្រៀមចំនួន ៤០០ខ្នងផ្ទះ បានផ្តល់ដីទំហំ ៧០មx១៥០ម ក្នុងមួយគ្រួសារ។

❖ **ធម្មការ សាសនា និងវប្បធម៌ ៖** ទូទាំងខេត្តមានវត្តអារាមចំនួន ២១៦កន្លែង និងអាស្រម ១៤កន្លែង មានព្រះសង្ឃសរុបចំនួន ២ ៦៧៥អង្គ តាជីយាយជី ៤៧៤នាក់។ សាសនាឥស្លាមមានវិហារចំនួន ៥៩កន្លែង និងសូរាវចំនួន ៥០កន្លែង។ សាសនាគ្រិស្តមានវិហារចំនួន ៧៥កន្លែង និងស្នាក់ការថ្វាយបង្គំចំនួន ១៥កន្លែង សាសនាទាំងអស់មានសុខដុមនីយកម្មល្អប្រសើ។ ខេត្តមានប្រាសាទបុរាណ ស្ថានីយបុរេប្រវត្តិ និងរមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រចំនួន ១៦កន្លែង ផ្ទះបុរាណ ៥កន្លែង វិហារបុរាណ ៣កន្លែង និងវត្ថុបុរាណដែលបានថែរក្សាទុកនៅសារមន្ទីរខេត្ត។

❖ **ការគ្រប់គ្រងគ្រោះមហន្តរាយ៖** រៀងរាល់ឆ្នាំខេត្តតែងតែរងគ្រោះធម្មជាតិដូចជា ស្ថានភាពទឹកជំនន់ គ្រោះរាំងស្ងួត គ្រោះឧបទ្ទវហេតុផ្សេងៗ បណ្តាលឲ្យមានផលប៉ះពាល់ដល់លំនៅដ្ឋាន ដំណាំស្រូវ និងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ និងធារាសាស្ត្រមួយចំនួន។ រដ្ឋបាលខេត្តបានចាត់កម្លាំងប្រតិបត្តិការចុះអន្តរាគមន៍ ដោះស្រាយបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋរងគ្រោះ ជាពិសេសផ្តល់ស្បៀងអាហារ គ្រឿងឧបភោគ បរិភោគ ជម្រក ទឹកស្អាត ថ្នាំសង្កូវ កម្លាំងប្រចាំការការពារសន្តិសុខ និងត្រៀមលក្ខណៈជាប់ជាប្រចាំក្នុងការជួយ និងជម្លៀសប្រជាពលរដ្ឋទៅទីទួលសុវត្ថិភាព ។ ជាក់ស្តែងឆ្នាំ២០២២ ប្រជាជនដែលបានរងផលប៉ះពាល់ដោយទឹកជំនន់បានទទួលព្រះរាជអំណោយពី **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត បានប្រោសព្រះរាជទានព្រះរាជអំណោយដល់ប្រជារាស្ត្ររងគ្រោះចំនួន **២៩២គ្រួសារ**។ រដ្ឋបាលខេត្ត សាខាកាកបាទក្រហមខេត្ត អនុសាខាកាកបាទក្រហមក្រុង ស្រុក និងក្រុមការងារបាននាំយកអំណោយដ៏ថ្លៃថ្លារបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**

នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ប្រធានកាកបាទក្រហមកម្ពុជា ចែកជូនប្រជាពលរដ្ឋរងគ្រោះចំនួន **២ ៣៧៣គ្រួសារ** ។ **សម្តេចចៅហ្វាវាំង គន់ គីម** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្ត **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្ត **ឯកឧត្តមទេសរដ្ឋមន្ត្រី គុយ សុផល** ឯកឧត្តមសមាជិកព្រឹទ្ធសភា ឯកឧត្តម លោកជំទាវអ្នកតំណាងរាស្ត្រ **ឯកឧត្តមបណ្ឌិត ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ **ឯកឧត្តមនាយឧត្តមសេនីយ៍ សឹង សំណាង** ឯកឧត្តម លោកជំទាវក្រុមការងារថ្នាក់កណ្តាល និងក្រុមការងាររាជរដ្ឋាភិបាលបានផ្តល់អំណោយជូនប្រជាពលរដ្ឋរងគ្រោះចំនួន **២ ២១១គ្រួសារ** សរុបទាំងអស់ចំនួន **៤ ៥៨៤ គ្រួសារ។** នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២២ ប្រជាពលរដ្ឋខេត្តកំពង់ឆ្នាំង មានកិត្តិយសដ៏ខ្ពង់ខ្ពស់បានទទួល **សម្តេចតេជោនាយករដ្ឋមន្ត្រី** អញ្ជើញចុះជួបសំណេះសំណាល និងចែកពូជស្រូវដល់ប្រជាកសិករដែលរងការខូចខាតដំណាំស្រូវ និងគ្រឿងឧបភោគ បរិភោគមួយចំនួនទៀតចំនួន **៣ ៤៦០គ្រួសារ។**

## ៥.ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្ត

ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជានៅខេត្តកំពង់ឆ្នាំង ក្រោមការដឹកនាំរបស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ឆ្នាំង **ឯកឧត្តម ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាអនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្ត និង**ឯកឧត្តម លោកជំទាវ** រដ្ឋលេខាធិការ និងជាប្រធាន អនុប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានក្រុង ស្រុក និងលោក លោកស្រី ជាសមាជិកក្រុមការងារមានសរុបចំនួន ៦៨១នាក់ (ស្រី១២២នាក់) ក្នុងនោះថ្នាក់ជាតិចំនួន ២៤៧នាក់ (ស្រី ៣៧នាក់) ថ្នាក់ក្រោមជាតិចំនួន ៤៣៤នាក់ (ស្រី៨៣នាក់)។ ក្រុមការងារបានធ្វើវេទិកាសាធារណៈ បានទទួលសំណើ សំណូមពរ និងសំណួររបស់ប្រជាពលរដ្ឋ បានឆ្លើយបំភ្លឺ និងបានដោះស្រាយជូនប្រជាពលរដ្ឋបានទាន់ពេលវេលា ហើយក្រុមការងាររាជរដ្ឋាភិបាលបានចូលរួមព្រឹត្តិការណ៍នានានៅមូលដ្ឋានជាប់ជាប្រចាំ ធ្វើសកម្មភាពអប់រំផ្សព្វផ្សាយអំពីវិធានការបង្ការជំងឺកូវីដ-១៩ ជំរុញការចាក់វ៉ាក់សាំង ចុះសួរសុខទុក្ខ ចែកអំណោយជូនប្រជាពលរដ្ឋធ្វើចត្តាឡីស័ក អ្នកមានវិជ្ជមានជំងឺកូវីដ-១៩ នៅគ្រប់ភូមិ ឃុំ សង្កាត់ទូទាំងខេត្ត ។

## ៦.ការអនុវត្តគោលនយោបាយ និងបទបញ្ជារបស់រាជរដ្ឋាភិបាល

**១.ការងារយុទ្ធនាការដកហូត និងគ្រប់គ្រងដីតំបន់៣ ជុំវិញបឹងទន្លេសាបៈ** តាមរយៈអនុក្រឹត្យលេខ១៩៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១១ ខេត្តកំពង់ឆ្នាំងមានព្រៃលិចទឹកតំបន់៣ សរុបទំហំ ៧៥ ០២៨,១២ ហិកតា គ្របដណ្តប់លើភូមិសាស្ត្រចំនួន ៣ស្រុករួមមានៈ ស្រុកកំពង់លែងមានផ្ទៃដីទំហំ ៦២ ០០៦,៣៦ហិកតា គ្របដណ្តប់លើ ៧ឃុំ មាន ២៧ភូមិ ស្រុកបរិបូណ៌មានផ្ទៃដីទំហំ ៨ ៨៤៥,៧៧ហិកតា គ្របដណ្តប់លើ ៧ ឃុំ មាន ២០ភូមិ និងស្រុកជលគិរី មានផ្ទៃដីទំហំ ៤ ១៧៦ហិកតា គ្របដណ្តប់លើ ១ឃុំ មាន ២ភូមិ ។ ការចុះអនុវត្តយុទ្ធនាការដកហូតដីព្រៃលិចទឹកក្នុងតំបន់៣ជុំវិញបឹងទន្លេសាប ប្រជាពលរដ្ឋស្ម័គ្រចិត្តធ្វើលិខិតប្រគល់ដីជូនរដ្ឋសរុបចំនួន ៧ ៥៣១គ្រួសារ ស្មើនឹងផ្ទៃដីសរុបទំហំ ៣០ ៥៨៩ហិកតា ក្នុងនោះស្រុកកំពង់លែងមាន

ចំនួន ៥ ០៨៥គ្រួសារ ស្មើនឹងផ្ទៃដីទំហំ ២៤ ០៩៥,៣២ហិកតា ស្រុកបរិបូណ៌ចំនួន ២ ០៥៣គ្រួសារ ស្មើនឹងផ្ទៃដីទំហំ ៤ ៩៩៩,៩៤ ហិកតា និងស្រុកជលគិរីចំនួន ៣៩៧គ្រួសារ ស្មើនឹងផ្ទៃដីទំហំ ១ ៤៩៣,៧៤ ហិកតា ។ ក្រុមការងារបានចុះវាស់វែងក្បាលដីតាមការចង្អុលបង្ហាញរបស់ប្រជាពលរដ្ឋដែលបានស្ម័គ្រចិត្តប្រគល់ដីជូនរដ្ឋរួចចំនួន ៣ ៧៨៨គ្រួសារ ស្មើនឹង ៤ ២៩០ក្បាលដីលើផ្ទៃដីសរុបទំហំ ១១ ៥៧៦,៣៨ហិកតា ៖ស្រុកកំពង់លែងចំនួន ១ ៦៧០គ្រួសារ ស្មើនឹង ១ ៨០៨ក្បាលដី សរុបទំហំ ៦ ៧២៥,៦៣ហិកតា ស្រុកបរិបូណ៌ចំនួន ១ ៨១៣គ្រួសារ ស្មើនឹង ២ ១៤៩ក្បាលដី សរុបទំហំ ៣ ៧៦៦,១៧ហិកតា និងស្រុកជលគិរីចំនួន ៣០៥ គ្រួសារ ស្មើនឹង ៣៣៣ ក្បាលដី សរុបទំហំ ១ ០៨៤,៥៨ហិកតា។

**២.ការងារកាត់ឆ្វៀលផ្ទៃដីជូនប្រជាពលរដ្ឋ៖** តាមអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់**សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី** និងក្រោមការដឹកនាំអនុវត្តផ្ទាល់ដោយ **ឯកឧត្តម ជា សុផារ៉ា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង**ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ និងជាប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្ត ថ្នាក់ដឹកនាំក្រុមការងារអន្តរក្រសួង និងរដ្ឋបាលខេត្តកំពង់ឆ្នាំង បានចុះពិនិត្យដីភូមិឋានរបស់ប្រជាពលរដ្ឋបានរស់នៅយូរលង់ណាស់មកហើយនិងដីអាស្រ័យផលពិតប្រាកដនៅក្នុងតំបន់២តំបន់ ៣ បានពីរលើករួចហើយគឺ៖

លើកទី១÷ កាលពីថ្ងៃទី២ ខែមិថុនា ឆ្នាំ២០២២ រាជរដ្ឋាភិបាល បានសម្រេចកាត់ឆ្វៀលដីទំហំ ២៥៣ ហិកតា ចេញពីតំបន់៣ និងផ្តល់ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៦ ៨៨ គ្រួសារ និងកែសម្រួលផ្ទៃដីទំហំ ៣ ៣៩១ ហិកតា ចេញពីតំបន់៣ បញ្ចូលជាតំបន់២ ជូនប្រជាពលរដ្ឋចំនួន ១៦ ៨៨ គ្រួសារសម្រាប់ប្រើប្រាស់ និងអាស្រ័យផល នៅឃុំសំរោងសែន និងឃុំផ្លូវទូក ស្រុកកំពង់លែង

លើកទី២÷ កាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២៣ រាជរដ្ឋាភិបាល បានសម្រេចកាត់ឆ្វៀលដីទំហំ ៧៤១,១៧ ហិកតា ចេញពីតំបន់៣ ដោយក្នុងនោះ÷

ផ្ទៃដីទំហំ **៤៤៣,៦៣ ហិកតា** ជាភូមិរៀបរយទទួលប្រជាពលរដ្ឋផ្លាស់ទីផ្ទះទឹកមកលើគោក នៅឃុំកំពង់ព្រះគគីរ ឃុំខុនរ៉ង ឃុំត្រពាំងចាន់ និងឃុំឆ្នុកទ្រូ ហើយធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដោយមិនអនុញ្ញាតទៅតាំងទីលំនៅជាថ្មីលើទឹកទៀតឡើយ។

ផ្ទៃដីទំហំ **២២២,៥៤ ហិកតា** ស្ថិតក្នុងនៅឃុំឆ្នុកទ្រូ ជូនរដ្ឋបាលខេត្តសម្រាប់គម្រោងវារីវប្បកម្ម និងផ្ទៃដីទំហំ **៧៥ ហិកតា** ស្ថិតក្នុងនៅឃុំឆ្នុកទ្រូ ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ជាមួយគ្នានោះ រាជរដ្ឋាភិបាល ក៏បានសម្រេចកែសម្រួលផ្ទៃដីទំហំ **៤៦ ៧០៨,៩៥ ហិកតា** នៅក្នុងក្រុងកំពង់ឆ្នាំង ស្រុកកំពង់ត្រឡាច ស្រុករលាប្អៀរ ស្រុកបរិបូណ៌ ស្រុកកំពង់លែង និងស្រុកជលគិរី ចេញពីតំបន់២ បញ្ចូលមកជាតំបន់១ នៃតំបន់ទន្លេសាប និងផ្តល់ជាកម្មសិទ្ធិជូនអ្នកកាន់កាប់ជាក់ស្តែងប្រហែល ៦ ម៉ឺនគ្រួសារ។

**៣.ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ៖** អនុវត្តតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់បំផុតរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** ឲ្យជំរុញការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ និងដោះស្រាយសំណូមពរនានាជូនប្រជាពលរដ្ឋ ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ឆ្នាំង និងរដ្ឋបាលខេត្ត បានធ្វើការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ និងសំណូមពរជូនប្រជាពលរដ្ឋនៅមូលដ្ឋានចំនួន ១០០៨ករណី បាន

សម្របសម្រួលដោះស្រាយបញ្ចប់ចំនួន ៩១៤ករណី និងករណីនៅសេសសល់កំពុងបន្តចុះដោះស្រាយជាបន្តបន្ទាប់ទៀត។

**៤-ការងារផ្សព្វផ្សាយទប់ស្កាត់ និងបង្ក្រាបបទល្មើសនេសាទ៖** នៅរដូវហាមឃាត់ការនេសាទជារៀងរាល់ឆ្នាំ គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្ត ក្រុង ស្រុក បានចុះផ្សព្វផ្សាយអប់រំប្រជាពលរដ្ឋពាក់ព័ន្ធនឹងការនេសាទនៅរដូវត្រីពង ការហាមឃាត់ប្រើឧបករណ៍នេសាទដែលច្បាប់ហាមឃាត់ និងបានផ្សព្វផ្សាយចលនាឲ្យអ្នកប្រើប្រាស់ឧបករណ៍ឆក់ត្រីស្ម័គ្រចិត្តប្រគល់ជូនសមត្ថកិច្ច ក្រុមប្រតិបត្តិការ ចម្រុះចុះបង្ក្រាបបទល្មើសជលផលក្នុងភូមិសាស្ត្រ បានដកហូត និងបំផ្លាញឧបករណ៍នេសាទខុសច្បាប់គ្រប់ប្រភេទ ។

**៥-ការងារបង្ក្រាបល្បែងស៊ីសងគ្រប់ប្រភេទ៖** អនុវត្តតាមគោលការណ៍ណែនាំ របស់រាជរដ្ឋាភិបាលស្តីពីការបង្ក្រាបការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទរដ្ឋបាលខេត្ត បានចាត់វិធានការរដ្ឋបាល ធ្វើកិច្ចសន្យាបិទទីតាំងល្បែងស៊ីសងគ្រប់ប្រភេទ ក្នុងនោះមានទីតាំងលេងល្បែងភ្នាល់តាម Internet ជ្រកក្រោមអាជីវកម្ម-អាជ្ញាបណ្ណ និងទីតាំងលេងល្បែងភ្នាល់ផ្សេងៗនៅក្នុងខេត្ត។

**៦.ការបន្លាស់ទីផ្ទះបណ្តែតទឹកឱ្យឡើងមករស់នៅលើគោក ក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង៖** នៅទូទាំងខេត្តប្រជាពលរដ្ឋខ្មែរ និងខ្មែរឥស្លាមបានបន្លាស់ទីផ្ទះបណ្តែតទឹកមករស់នៅលើគោកមានចំនួន ២ ៣៣៦ខ្នងផ្ទះ និងជនអន្តោប្រវេសន៍វៀតណាមចំនួន ១៧៨៥ខ្នងផ្ទះ។ បានរៀបចំបន្លាស់ទីផ្ទះបណ្តែតទឹករបស់ប្រជាពលរដ្ឋមករស់នៅលើគោគនៅតំបន់ដី ៤០ហិកតាមានចំនួន ៦១១ខ្នងផ្ទះ។ បែរចិញ្ចឹមត្រីមានចំនួន ៣៧២បែរ ស្មើនឹង ២៣១គ្រួសារ នៅត្រើយខាងកើតចំនួន ១៧៩បែរ ស្មើនឹង ១០១គ្រួសារ និងនៅត្រើយខាងលិចចំនួន ១៩៣បែរ ស្មើនឹង ១៣០គ្រួសារ ទូកដំបូលស្នាក់នៅអចិន្ត្រៃយ៍លើផ្ទះទឹកចំនួន ៨០គ្រឿង ស្មើនឹង៨០គ្រួសារ។ ពាក់ព័ន្ធនឹងបែរចិញ្ចឹមត្រី និងទូកមានដំបូលនេះ ក្រុមការងារបានរុះរើ និងកាត់ដំបូលចេញសម្រេចបាន ១០០%។ រដ្ឋបាលខេត្តបានសាងសង់ ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្រួសក្រហម ផ្លូវកៅស៊ូ កសាងរង្វង់មូល សាងសង់ផ្សារកំពង់ឆ្នាំងថ្មីនៅភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង និងបានបន្លាស់ទីតូបលក់ដូរជួរដើមស្រល់មុខវត្តយាយទេពចំនួន ១៩៦តូប ។ សាងសង់សំណង់ផែថ្មីនៅភូមិទី៧ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង សាងសង់ចំណតរថយន្តទំហំ (៥០មx៤០ម) បានរៀបចំចាក់ដីទំហំ ២២ហិកតា រៀបចំហេដ្ឋារចនាសម្ព័ន្ធបណ្តាញទឹកភ្លើង ផ្លូវ ប្រព័ន្ធលូ អាងចម្រោះ នៅលើផ្ទៃដីទំហំ ៤០ហិកតាដែលរាជរដ្ឋាភិបាលបានអនុញ្ញាត សម្រាប់អភិវឌ្ឍន៍សង់លំនៅឋានជូនប្រជាពលរដ្ឋខ្មែរ ខ្មែរឥស្លាម និងជនអន្តោប្រវេសន៍វៀតណាមដែលរស់នៅលើផ្ទះបណ្តែតទឹកឲ្យមកជួលដីសម្រាប់សង់ទីលំនៅលើគោកស្របតាមផែនការរៀបចំបន្លាស់ទីរបស់រដ្ឋបាលខេត្ត។

**៧.ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣**

អនុវត្តតាមច្បាប់ស្តីពីការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងអនុវត្តតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងប្រតិទិននៃការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្រោមការដឹកនាំរបស់ **សម្តេចចៅហ្វាវាំង គង់ សំអុល** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ប្រធានក្រុមការងារចុះមូលដ្ឋានខេត្ត **ឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន** រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ប្រធានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្ត **ឯកឧត្តមទេសរដ្ឋមន្ត្រី គួយ សុផល** ឯកឧត្តមសមាជិកព្រឹទ្ធសភា ឯកឧត្តម លោកជំទាវអ្នកតំណាងរាស្ត្រ **ឯកឧត្តមបណ្ឌិត ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ **លោកជំទាវ ជូ ប៊ុនអេង ឯកឧត្តមនាយឧត្តមសេនីយ៍ ស៊ីង សំណាង** អនុប្រធានក្រុមការងារ ឯកឧត្តម លោកជំទាវ ក្រុមការងាររាជរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់បានអនុវត្តដូចខាងក្រោម៖

### ៧.១.បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០២២

ដំណើរការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០២២នៅគ្រប់ការិយាល័យបោះឆ្នោត ទាំង ៨០៧ក្នុងខេត្ត មានប្រជាពលរដ្ឋច្រើនកុះករបានទៅបោះឆ្នោត និងដំណើរការបោះឆ្នោតបានអនុវត្តតាមនិតិវិធី ហើយសភាពការណ៍នយោបាយ សន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់ល្អប្រសើ។ ប្រជាពលរដ្ឋមានឈ្មោះក្នុង បញ្ជីបោះឆ្នោតចំនួន ៣៤៣ ៣៦៨នាក់ ប្រជាពលរដ្ឋទៅបោះឆ្នោតចំនួន ២៩០ ៨៧២នាក់ ស្មើនឹង ៨៤,៧១% នៃអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ។ គណបក្សប្រជាជនកម្ពុជាទទួលបាន ២០២ ៩៥៧សំឡេង ស្មើនឹង ៧១,៤០% នៃសន្លឹកឆ្នោតបានការសរុប ។ គណបក្សប្រជាជនកម្ពុជាទទួលបាន ៣៣៧អាសនៈ ស្មើនឹង ៧៨,៩២% នៃចំនួនអាសនៈសរុប និងគណបក្សភ្លើងទៀនទទួលបានចំនួន ៩០អាសនៈ ស្មើនឹង ២១,០៨% នៃចំនួនអាសនៈសរុប។ ប្រៀបធៀបឆ្នាំ២០២២ និងឆ្នាំ២០១៧ គណៈបក្សប្រជាជនកម្ពុជាទទួលអាសនៈ ក្រុមប្រឹក្សាឃុំ សង្កាត់ កើនចំនួន ៨៥ អាសនៈ តំណែងមេឃុំចៅសង្កាត់កើន ៩ឃុំ សង្កាត់ ។ គណៈបក្ស ភ្លើងទៀន ថយចុះ ៨០អាសនៈ តំណែងមេឃុំ ចៅសង្កាត់ថយចុះ ៧ឃុំ សង្កាត់។ គណបក្សប្រជាជនកម្ពុជាបានឈ្នះ ដាច់ចំនួន ២ឃុំ សង្កាត់គឺ សង្កាត់ខ្សាម ក្រុងកំពង់ឆ្នាំង ៥អាសនៈ និងឃុំកុលសែនជ័យ ស្រុកទឹកផុស ៥អាសនៈ ។

### ៧.២.បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៧ ឆ្នាំ២០២៣

គណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តបានចាត់តាំងអនុវត្តសកម្មភាពការងារតាមប្រតិទិននៃការបោះឆ្នោត របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។ បានណែនាំឲ្យប្រជាពលរដ្ឋដែលគ្រប់អាយុទៅធ្វើអត្តសញ្ញាណ ប័ណ្ណគ្រប់ៗគ្នា ដើម្បីឲ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់បម្រើឲ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ នាពេលខាងមុខ ។ អាជ្ញាធរមូលដ្ឋានបានចលនាប្រជាជនដែលគ្រប់អាយុបោះឆ្នោត ទៅចុះ ឈ្មោះបោះឆ្នោត លទ្ធផលការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០២២ ក្នុងរយៈពេល៥០ថ្ងៃនៃ ការចុះឈ្មោះបោះឆ្នោតពីថ្ងៃទី២០ ខែតុលា ដល់ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២២ ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះ បោះឆ្នោតនៅតាមឃុំ សង្កាត់ទាំង ៧១ឃុំ សង្កាត់ ប៉ាន់ស្មានមនុស្សអាយុ១៨ឆ្នាំឡើងចំនួន ៣៨១ ១៩៥នាក់ ផែនការចុះឈ្មោះបោះឆ្នោតថ្មីចំនួន ១៤ ២១២នាក់ ចំនួនក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០២១មាន ៣៤៣ ៣៦៨នាក់ ចុះឈ្មោះបោះឆ្នោតថ្មីចំនួន១៩ ៦៣២នាក់ ស្មើ ១៣៨,១៤% នៃផែនការ និងផ្ទេរចូលពីក្រៅឃុំ សង្កាត់ចំនួន ៥ ៤៥៤នាក់។ ការលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយស្លាប់ ដកសិទ្ធិ ផ្លាស់ចេញចំនួន ៣ ៣២៨នាក់ ផ្ទេរ ចេញក្រៅឃុំ សង្កាត់ចំនួន ៥ ១៧០នាក់ ប្តូរការិយាល័យក្នុងឃុំ សង្កាត់ ៣ ២០០នាក់ និងកែតម្រូវទិន្នន័យក្នុង បញ្ជីចំនួន ៣ ៣៤៩នាក់ ។ លទ្ធផលបណ្តោះអាសន្នក្នុងបញ្ជីបោះឆ្នោតមានចំនួនឈ្មោះក្នុងបញ្ជីបោះឆ្នោត ចំនួន ៣៥៩ ៩៥៦នាក់ ចំនួនអ្នកបោះឆ្នោតកើនឡើងក្នុងបញ្ជីចំនួន ១៦ ៥៨៨នាក់ ចំនួនការិយាល័យបោះ ឆ្នោត ឆ្នាំ២០២២សរុប ៨១៨ការិយាល័យ (ការិយាល័យបង្កើតថ្មីចំនួន ១១ការិយាល័យ)។

## ៨.ទិសដៅបន្ត

១.អនុវត្តយ៉ាងម៉ឺងម៉ាត់ និងត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ច្បាប់ គោលនយោបាយ បទបញ្ជា លិខិតបទដ្ឋាន គតិយុត្តរបស់រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័ននានា។ ពង្រឹងប្រសិទ្ធិភាព ការគ្រប់គ្រងរដ្ឋបាល ដែនដី អនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ស៊ីជម្រៅរបស់ រាជរដ្ឋាភិបាល។

២.លើកម្ពស់ការរក្សាសន្តិសុខនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ឲ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីភាពសុខដុមរមនារបស់ប្រជាពលរដ្ឋ។ បន្តលើកកម្ពស់ការរក្សាសន្តិសុខនយោបាយ និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ និងអនុវត្តសកម្មភាពការងារតាមប្រតិទិន នៃការបោះឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

៣.ជំរុញការអនុវត្តផែនការអភិវឌ្ឍន៍ខេត្តរយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ក្រុមប្រឹក្សាខេត្ត ការអនុវត្តផែនការតាមវិស័យ និងជំរុញការអភិវឌ្ឍន៍គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ធារាសាស្ត្រ អប់រំ សុខាភិបាល ដើម្បីជំរុញការអភិវឌ្ឍជីវភាពរស់នៅឲ្យប្រសើរឡើង ថែរក្សាសុខុមាលភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ។

៤.បន្តរៀបចំផែនការ និងជំរុញល្បឿននៃការអភិវឌ្ឍតាមវិស័យ ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជនដូចខាក្រោម៖

- **ការអភិវឌ្ឍវិស័យកសិកម្ម**៖ លើកកម្ពស់ការផ្តល់បច្ចេកទេសផលិតកម្មកសិកម្ម ដល់កសិករ ដើម្បីអភិវឌ្ឍន៍បង្កើនផលិតភាព តាមរយៈការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម របស់រាជរដ្ឋាភិបាល ជំរុញការចិញ្ចឹមសត្វ វារីវប្បកម្ម ការដាំដុះដំណាំកសិ-ឧស្សាហកម្ម និងបន្តអភិវឌ្ឍន៍សហគមន៍កសិកម្មដើម្បីផលិតផលិតផលកសិកម្មដែលជាតម្រូវការទីផ្សារ និងជួសជុល ស្តារប្រព័ន្ធប្រឡាយ សំណង់ធារាសាស្ត្រ ដើម្បីស្រោចស្រពផ្ទៃដីដាំដុះ ។
- **ការអភិវឌ្ឍវិស័យឧស្សាហកម្ម សិប្បកម្ម** ៖ ជំរុញការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ផ្តល់ឱកាសជំរុញឲ្យបរិស្ថានវិនិយោគល្អប្រសើ ជាមួយវិស័យឯកជនដើម្បីមកវិនិយោគ នៅខេត្តកំពង់ឆ្នាំង ដើម្បីឲ្យប្រជាពលរដ្ឋមានការងារធ្វើ ទទួលបានប្រាក់ចំណូល និងលើកកម្ពស់ជីវភាពរស់នៅ
- **ពង្រឹងការគ្រប់គ្រងដីធ្លី**៖ រៀបចំប្លង់គោល ផែនការប្រើប្រាស់ដីធ្លី ការស្នើសុំកាត់ឆ្វៀលដីសម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋពីដីតំបន់៣ មកជាដីតំបន់២ ពីដីតំបន់២ មកតំបន់១ និងដីតំបន់១ ខ្លះផ្តល់កម្មសិទ្ធិជូនប្រជាជន និងការអភិវឌ្ឍវិស័យសំណង់ហេដ្ឋារចនាសម្ព័ន្ធគ្រប់ប្រភេទតាមលិខិតបទដ្ឋានជាធរមាន ។
- **ការអភិវឌ្ឍវិស័យសេវាកម្ម**៖ អភិវឌ្ឍផ្សារឲ្យមានបរិស្ថានល្អ សម្រាប់ប្រជាជនធ្វើអាជីវកម្ម បង្កើនការគ្រប់គ្រងការលក់ដុំ លក់រាយទំនិញគ្រប់ប្រភេទ មានគុណភាព និងតម្លៃសមរម្យ
- **អភិវឌ្ឍគោលដៅទេសចរណ៍សំខាន់ៗ**៖ រៀបចំអភិវឌ្ឍតំបន់ទេសចរណ៍ធម្មជាតិ តំបន់ទេសចរណ៍វប្បធម៌ប្រវត្តិសាស្ត្រ និងអភិវឌ្ឍសេវាទេសចរណ៍ សណ្ឋាគារ ផ្ទះសំណាក់ សេវាកំសាន្ត ភោជនីយដ្ឋាន...)ឲ្យបានល្អប្រសើ បង្កើនផលិតផលទេសចរណ៍ ជំរុញចលនាប្រឡងប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត ទីក្រុងបៃតង
- **ការអភិវឌ្ឍវិស័យសង្គមកិច្ច**៖ បន្តជំរុញការអភិវឌ្ឍវិស័យអប់រំ សុខាភិបាល សង្គមកិច្ច ដើម្បីឲ្យប្រជាជនមានចំណេះដឹង សុខុមាលភាពល្អប្រសើ សម្រាប់ជាធនធានមនុស្សដ៏មានសក្តានុពលក្នុងការចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងអនុវត្តគោលនយោបាយគាំពារសង្គមនានារបស់រាជរដ្ឋាភិបាលក្នុងការជួយគាំទ្រឲ្យប្រជាជនរស់នៅមានជីវភាពល្អប្រសើ។

ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងស្ថាប័នថ្នាក់ជាតិ រដ្ឋបាលខេត្តកំពង់ឆ្នាំង សម្រេចបាននូវសមិទ្ធផលធំៗ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដោយបានអនុវត្តត្រឹមត្រូវតាមគោលការណ៍នីតិរដ្ឋ និងអនុវត្តការងារស្របតាមបែបបទលិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ច្បាប់ ។ មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន បានចូលរួមយ៉ាងសកម្មក្នុងការថែរក្សា ពង្រឹងសន្តិភាព សន្តិសុខសណ្តាប់ធ្នាប់សង្គមនៅមូលដ្ឋាន និងការលើកកម្ពស់ជីវភាពរស់នៅរបស់ខ្លួន។

ថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំង និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ នឹងបន្តខិតខំជំរុញការអភិវឌ្ឍជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅទូទាំងខេត្ត លើកស្ទួយសុខមាលភាព កាត់បន្ថយភាពក្រីក្រ ក៏ដូចជាទិសដៅភារកិច្ចដាក់ចេញដោយក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័នពាក់ព័ន្ធ ដោយឈរលើស្មារតីឆន្ទៈមោះមុត មានការប្តេជ្ញាចិត្តខ្ពស់ និងមានសាមគ្គីឯកភាព ដើម្បីសម្រេចជោគជ័យថ្មីៗ ថែមទៀត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។

**សូមអរគុណ** !